# OUSTER-20

## ថ្នាំបកថ្នាំ - Paint Remover




## ការពិពណ៌នាពីផលិតផល

**OUSTER-20** ជាប្រភេទថ្នាំបកថ្នាំ ដែលផ្សំឡើងពី Chlorinated Paint Remover ប្រើបកបានទៅលើប្រភេទថ្នាំដូចជា៖ ថ្នាំប្រេងលាបលើដែក, វ៉ារនីស (Varnish) ឬឡេកគ័រ (Lacquer) លាបលើឈើ,ផ្ទៃដែលប្រើប្រាស់អ៊ីប៉ុកស៊ី (Epoxy) និងបកបានលើប្រភេទថ្នាំមួយចំនួនផ្សេងទៀត។

## របៀបប្រើប្រាស់

ត្រូវលាបផ្ទាល់លើផ្ទៃថ្នាំ ដែលយើងចង់បក បន្ទាប់មកយើងទុកវាប្រហែល 5-10 នាទី វានឹងចាប់ផ្តើមធ្វើឱ្យផ្ទៃមុខថ្នាំប្រេះប៉ោងៗ រួចហើយយើងធ្វើការឈូសសម្អាតឱ្យស្អាតជាមុនសិន ដោយប្រើស្លាបព្រាឈូសហើយបន្ទាប់មក យើងយកក្រណាត់ជ្រលក់ជាមួយប្រេងលាយជូតសម្អាតម្តងទៀត ដើម្បីឱ្យប្រាកដថាផ្ទៃ ដែលត្រូវបកបានស្អាតល្អ។

## ទំហំគ្របដណ្តប់

4-5$m^2$ /Kg ឬប្រហែល 11$m^2$ /កំប៉ុង

## ឧបករណ៍ប្រើប្រាស់

ប្រើជក់ ឬរ៉ូឡូ (នៅពេលប្រើប្រាស់សូមពាក់ស្រោមដៃជ័រ,វ៉ែនតាការពារ និងម៉ាស់)

## ប្រការគួរប្រុងប្រយ័ត្ន

- សូមធ្វើការបើកគម្រប ដោយមានការប្រុងប្រយ័ត្ន កុំឱ្យក្មេងលេង និងទុកឱ្យឆ្ងាយពីអណ្តាតភ្លើង
- ប្រសិនមានករណីទឹកថ្នាំខ្ទាតប៉ះលើស្បែក ឬភ្នែក សូមប្រញាប់លាងសម្អាតជាមួយទឹកជាបន្ទាន់។







CAM-PAINT
ថ្នាំពណ៌ជាតិ

# ថ្នាំលាបប្រភេទឧស្សាហកម្ម

# INDUSTRIAL PAINT




ផ្លូវលេខ 217(ផ្លូវជើងឯក) ភូមិក្រាំងស្វាយ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ
www.campaint-ccsc.com.kh
info@campaint-ccsc.com.kh
Cam-Paint ថ្នាំពណ៌ជាតិ
Cam-Paint ថ្នាំពណ៌ជាតិ
សម្រាប់ផ្នែកប្រឹក្សាយោបល់៖ ☎ 016 595 909 / 078 885 443

# WABER

### ថ្នាំលាប អ៊ីប៉ុកស៊ី ប្រភេទលាយទឹក (2K)

### 2K WATER-BASED EPOXY PAINT




## ការពិពណ៌នាពីផលិតផល

**WABER** គឺជាថ្នាំលាបអ៊ីប៉ុកស៊ីប្រភេទលាយទឹកដំបូងគេនៅកម្ពុជា ដែលបានផលិតឡើងដោយឆ្លងកាត់ការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ពីក្រុមហ៊ុនខេមបូឌាន ខេមីខល សឺបផ្លាយ (ខាំ-ផេន)។

**WABER** ថ្នាំលាបអ៊ីប៉ុកស៊ីប្រភេទលាយទឹកមាន 2ផ្នែក (2K): ផ្នែក A គឺជាការស្និត និងផ្នែក B គឺជាការរឹងពិសេស។ នៅពេលដែលផ្នែកទាំង2នេះបញ្ចូលគ្នា វានឹងក្លាយជាផលិតផលមួយយ៉ាងល្អ លាយសម្រាប់លាបកម្រាលបាតបេតុង និងជញ្ជាំងបាយអដែលជាផ្ទៃនៅក្រោមម្លប់មានដូចជា ឃ្លាំងស្តុកទំនិញ កន្លែងជួសជុលរថយន្ត ការិយាល័យ សាលារៀន មន្ទីរពេទ្យ ផ្សារទំនើប ចំណតរថយន្ត អាហារដ្ឋាន បន្ទប់ពិសោធន៍ និងកន្លែងផ្សេងទៀត។ ក្រោយពីលាប **WABER** យើងនឹងទទួលបានផ្ទៃសាច់ភ្លឺរលោងល្មម ធន់នឹងសំណើក ធន់នឹងសារធាតុគីមី ហើយតោងស្អិតនឹងផ្ទៃបានយ៉ាងល្អ។

## ការរៀបចំផ្ទៃ

ផ្ទៃដែលត្រូវលាប ត្រូវតែស្ងួតរឹងមាំល្អគ្រប់គ្រាន់ រាបស្មើល្អ គ្មានធូលី ឬសារធាតុកខ្វក់ផ្សេងៗ។ បើសិនជាផ្ទៃដែលត្រូវលាបមានស្នាមប្រេះ ផតខូង និងប្រហោងសំបុកឃ្មុំត្រូវជួសជុលបិទភ្ជិតវាឱ្យបានស្អាតល្អមុនលាប **WABER**។ ហើយលក្ខខណ្ឌដែលសំខាន់មួយទៀតគឺផ្ទៃដែលត្រូវលាប គួរមានសំណើមទាបជាង ឬស្មើ 4ភាគរយ(%)។

## របៀបប្រើប្រាស់

**របៀបលាយ** : ត្រូវលាយ Part A(resin)=1kg ជាមួយ Part B(hardener)=6kg (A+B = 7kg) រួចកូរវាឱ្យសព្វសាច់ល្អ ដោយម៉ូទ័រកូរដែលមានល្បឿនពី 400 ទៅ 600 ជុំ/នាទី ប្រមាណ 2នាទី

**អាយុកាល** : សូមកុំទុកល្បាយ ដែលបានលាយបញ្ចូលគ្នារួច លើសពី 2 ម៉ោង

**រយៈពេលលាប** : ត្រូវទុកឱ្យបានយ៉ាងតិច10ម៉ោងមុនលាបទឹកបន្ទាប់

**ទំហំគ្របដណ្តប់** : 2 – 3 $m^2$/kg (លាប2ទឹក)

**ការពង្រាវ** : យើងអាចលាយទឹកស្អាតថែមបានប្រហែល 10ភាគរយ(%)

**ឧបករណ៍ប្រើប្រាស់**: ប្រើជក់ ឬរ៉ូឡូ

## ប្រការគួរប្រុងប្រយ័ត្ន

ទុកកុំឱ្យត្រូវកម្តៅថ្ងៃខ្លាំង ឆ្ងាយពីអណ្តាតភ្លើង និងទុកឱ្យផុតពីដៃក្មេង ។





